ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ ច័ន្ទ ២ កើត ខែ អស្សុជ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៩*

## សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មានស្តីពី
## ជំនួបសំដែងការគួរសមរវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ជាមួយក្រុមការងារបេសកកម្ម Article IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)

នារសៀលថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតឱ្យក្រុមការងារបេសកកម្ម Article IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដឹកនាំដោយលោក **Jarkko Turunen** ជាប្រធានបេសកកម្ម និងរួមជាមួយសមាជិកប្រតិភូ ចូលជួបសម្តែងការគួរសម ក្នុងពេលចុះបំពេញបេសកកម្មសម្រាប់រយៈពេល ២ សប្តាហ៍ នៅកម្ពុជា ។ បេសកកម្មនេះ មានគោលបំណង÷

១. វាយតម្លៃអំពីស្ថានភាពសេដ្ឋកិច្ចសកល, តំបន់ និងនយោបាយភូមិសាស្ត្រ មកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចកម្ពុជា,
២. វាយតម្លៃ និងផ្តល់អនុសាសន៍គន្លឹះសម្រាប់ពិចារណាលើវិធានការគោលនយោបាយជាយុទ្ធសាស្ត្រ និងអាទិភាពដែលរាជរដ្ឋាភិបាលកម្ពុជា បានកំពុងអនុវត្ត និងត្រៀមនឹងដាក់ចេញសម្រាប់ជំហានបន្ទាប់,
៣. ការប៉ាន់ស្មានតម្រូវការ និងប្រភពហិរញ្ញប្បទានក្នុងការគាំទ្រក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា (CSDGs) និង
៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពមន្ត្រីជំនាញកម្ពុជា ដែលរួមមាន ជំនាញវិភាគ និងស្តង់ដារគ្រប់គ្រងនិងផ្សព្វផ្សាយទិន្នន័យ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលជានិច្ចកាលតែងតែពង្រឹងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ក្នុងការចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រទេសកម្ពុជា, បន្តរួមចំណែករក្សានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងលើកកម្ពស់សមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញរបស់កម្ពុជា លើការវាយតម្លៃហានិភ័យក្នុងនិងក្រៅ និងប្រែក្លាយបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាទាំងឡាយ

ឱ្យទៅជាកាលានុវត្តភាពសម្រាប់កម្ពុជា តាមរយៈការដាក់ចេញនូវវិធានការកែទម្រង់ជាយុទ្ធសាស្ត្រ និងជាកញ្ចប់ ក្នុងរយៈពេល ខ្លី, មធ្យម និងវែង ប្រកបដោយភាពបុរេសកម្ម, ភាពប្រទាក់ក្រឡា និងភាពគ្រប់ជ្រុងជ្រោយ ។

លោក **Jarkko Turunen** ប្រធានបេសកកម្ម បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបាននូវសមិទ្ធផលកំណើនសេដ្ឋកិច្ចខ្ពស់ និងចំណូលជាតិប្រកបដោយភាពរឹងមាំ និង ផ្លែផ្កា ។ លោកក៏បានថ្លែងអំណរគុណដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបន្តរៀបចំផ្តល់កិច្ចសហការយ៉ាងសកម្ម សម្រាប់ក្រុមការងារបេសកកម្ម Article IV ក្នុងការវាយតម្លៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចកម្ពុជា និងពិភាក្សាដោយផ្ទាល់ ជាមួយអគ្គនាយកដ្ឋាន/ស្ថាប័នពាក់ព័ន្ធ ក្នុងឱកាសបំពេញការងារបេសកកម្មនេះ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានគូសបញ្ជាក់ផងដែរថា ក្របខ័ណ្ឌប៉ាន់ស្មានតម្រូវការ និងប្រភពហិរញ្ញប្បទានក្នុងការគាំទ្រគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា គួរត្រូវគិតគូរ និងផ្សារភ្ជាប់ជាមួយក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា, ផែនការយុទ្ធសាស្ត្រ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរយៈពេលមធ្យម ដែលបានអនុម័តរួច ។ ទន្ទឹមនេះ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានថ្លែងសេចក្តីសោមនស្សរីករាយ ចំពោះក្រុមការងារបេសកកម្ម Article IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដែលតែងតែលើកកម្ពស់ភាពជាដៃគូ និងភាពជាម្ចាស់ការ, ផ្តល់ការគាំទ្រ និងផ្តល់អនុសាសន៍ពិតប្រាកដតាមរយៈការចុះសង្កេត និងធ្វើការវាយតម្លៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចកម្ពុជាដោយផ្ទាល់ ចូលរួមចំណែកតម្រង់និងតម្រឹមគោលនយោបាយអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច, សង្គម, សារពើពន្ធ និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជាប្រកបដោយប្រសិទ្ធភាព ចីរភាព និងបរិយាប័ន្ន ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានជូនពរលោក Jarkko Turunen ព្រមទាំងសហការី ឱ្យទទួលបាននូវភាពជោគជ័យក្នុងឱកាសបំពេញការងារបេសកកម្មរបស់ខ្លួននៅកម្ពុជា និងសង្ឃឹមយ៉ាងមុតមាំថាក្រុមការងារនឹងផ្តល់អនុសាសន៍គន្លឹះបន្ថែមសម្រាប់ចូលរួមការអភិវឌ្ឍកម្ពុជា ។